ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១០.សរ.......

# សារាចរ

## ស្តីពី

## ការថែរក្សា ការពារបង្គោលព្រំដែនចាស់ បោះដោយគណៈកម្មការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងកូសាំងស៊ីន នៅមុន និងក្រោយ ទសវត្សរ៍ឆ្នាំ១៨៧០

ដើម្បីជៀសវាងការបាត់បង់នូវមរតកប្រវត្តិសាស្ត្រ ដែលជាផ្នែកមួយនៃសាវតាជាតិខ្មែរ និងការសឹករេចរឹលដោយធម្មជាតិ និងដើម្បីថែរក្សា ការពារបង្គោលព្រំដែនចាស់ដែលបោះដោយគណៈកម្មការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងកូសាំងស៊ីន នៅមុន និងក្រោយទសវត្សរ៍ឆ្នាំ១៨៧០ ឲ្យបានឋិតថេរគង់វង្ស ទុកឲ្យកូនចៅជំនាន់ក្រោយៗបានឃើញអតីតបង្គោលព្រំដែនទាំងនោះ និងធ្វើការប្រៀបធៀបជាមួយនឹងបង្គោលព្រំដែនបោះនៅជំនាន់ក្រោយនេះ នៅពេលដែលកម្ពុជាមានអធិបតេយ្យភាពពេញលេញក្នុងការធ្វើព្រំដែនជាមួយនឹងប្រទេសជិតខាង ដែលជាមោទនភាពជាតិមួយ ទុកសម្រាប់ខ្មែរជំនាន់ក្រោយជានិរន្តរ៍តទៅ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដូចខាងក្រោម៖

១-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ចាំបាច់ត្រូវរក្សាបង្គោលព្រំដែនចាស់ទាំងឡាយនោះឲ្យបានគង់វង្ស ទោះជាមានសភាពទ្រុឌទ្រោមកំរិតណាក៏ដោយ

២-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ត្រូវសហការជាមួយនឹងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ រក្សាទុកបង្គោលព្រំដែនចាស់ដែលបាក់ចេញពីគ្រឹះរបស់វា នៅកន្លែងមួយដែលមានសុវត្ថិភាព ដើម្បីទុកឲ្យប្រជាពលរដ្ឋទូទៅបានឃើញ និងស្គាល់

៣-ក្នុងករណីដែលបង្គោលចាស់ទាំងនោះ បាក់ចេញពីគ្រឹះ ដែលពុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជា គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន មានភារកិច្ចធ្វើការចរចាជាមួយភាគីវៀតណាមស្នើយកបង្គោលព្រំដែនទាំងនោះ មករក្សាទុកនៅកម្ពុជា

៤-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ រួមនឹងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែន ត្រូវសហការគ្នា ដើម្បីស្វែងរកបង្គោល ឬគ្រឹះបង្គោលព្រំដែនចាស់

ដែលអាចនៅសេសសល់ ដើម្បីប្រមូល ឬចងក្រងទុកជាឯកសារស្រាវជ្រាវ

៥-អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ ត្រូវសហការជាមួយនឹងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ដើម្បីថែរក្សា និងការពារបង្គោលព្រំដែនដែលប្រទេសទាំងពីរបានឯកភាពគ្នាបោះលើដីជាក់ស្តែងរួចហើយ ឲ្យបានឋិតឋេរគង់វង្សតរៀងទៅ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត ក្រុង ឃុំ សង្កាត់ ដែលជាប់ព្រំដែន មន្ទីរ និងអង្គភាពជំនាញជុំវិញខេត្តដែលជាប់ព្រំដែន ត្រូវចាត់ចែងឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិកាដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-គ្រប់រដ្ឋបាលខេត្តជាប់ព្រំដែន

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ